# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៣៩

## ស្តីពី
## លក្ខន្តិកៈដោយឡែក
## ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ

# យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១១ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីច្បាប់បន្ថែមទៅលើមាត្រា ៤០ ក្នុងជំពូកទី ៨ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

បង្កើតលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ "ក" ដូចមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា២.-**

មន្ត្រីជាន់ខ្ពស់សវនកម្មនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃអាជ្ញាធរសវនកម្មជាតិ តាមបទប្បញ្ញត្តិនៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា៣.-**

ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម មានឧបនិស្ស័យសម្រាប់បំពេញមុខតំណែងក្នុងការរៀបចំ និងដឹកនាំការងារសវនកម្ម សិក្សា និងផ្តល់យោបល់ក្នុងក្របខណ្ឌការងាររបស់អាជ្ញាធរសវនកម្មជាតិ។

## ជំពូកទី២

## ឋានន្តរសក្តិ និងមុខតំណែង

**មាត្រា៤.-**

ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មរួមមាន ៣ ឋានន្តរសក្តិ :

- ឋានន្តរសក្តិទី ១ : សវនករដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរសក្តិទី ២ : សវនករដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរសក្តិទី ៣ : សវនករ មាន ១៤ ថ្នាក់ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៥.-**

មន្ត្រីក្នុងឋានន្តរសក្តិសវនករដើមខ្សែពិសេស មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអគ្គលេខាធិការ អគ្គលេខាធិការរងឬថ្នាក់ស្មើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរសវនកម្មជាតិ ។

មន្ត្រីក្នុងឋានន្តរសក្តិសវនករដើមខ្សែ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាប្រធាននាយកដ្ឋានឬ ថ្នាក់ស្មើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរសវនកម្មជាតិ ។

មន្ត្រីក្នុងឋានន្តរសក្តិសវនករ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធាននាយកដ្ឋាន ឬ ថ្នាក់ស្មើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរសវនកម្មជាតិ ហើយមុខតំណែងនេះ ត្រូវសម្រេច ដោយអគ្គសវនករ ។

មន្ត្រីក្នុងឋានន្តរសក្តិខាងលើនេះ មិនអាចត្រូវចាត់ឱ្យទៅធ្វើកិច្ចការស្ថិតក្រោមការបង្គាប់របស់មន្ត្រីម្នាក់ទៀត ដែលមានឋានន្តរសក្តិថ្នាក់ទាបជាងខ្លួនលើកលែងតែមានករណីចាំបាច់ ហើយសាមីខ្លួនដែលមានឋានន្តរសក្តិថ្នាក់ ធំជាងនោះយល់ព្រម ។

## ជំពូកទី៣
## ការជ្រើសរើស

**មាត្រា៦.-**

ការជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងក្នុង ចំណោមបេក្ខជនជាមន្ត្រីរាជការ ឬ /និងក្នុងចំណោមនិស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើសនេះត្រូវកំណត់ឡើង ដោយរាជរដ្ឋាភិបាលតាមសំណើរបស់អគ្គសវនករ ។

**មាត្រា៧.-**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបើកចំហ ចំពោះបេក្ខជនដែលបានបំពេញនូវលក្ខខណ្ឌដូចខាង ក្រោម ÷

- មានសញ្ជាតិជាខ្មែរ
- មានអាយុច្រើនបំផុត ៣០ ( សាមសិប ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មានសញ្ញាបត្រទាបបំផុតបរិញ្ញាបត្រឬសញ្ញាបត្រដែលមានតម្លៃស្មើតាមមុខជំនាញ ដែលអាជ្ញាធរ សវនកម្មជាតិត្រូវការ
- មិនបានប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី និងសិទ្ធិជាពលរដ្ឋ និងសិទ្ធិខាងនយោបាយ
- មិនដែលមានទោសមជ្ឈិម ឬ ឧក្រិដ្ឋពីបទល្មើសប៉ះពាល់ដល់ទំនៀមទម្លាប់ កិត្តិយស និង ភាពសុចរិត និង
- ត្រូវមានសុខភាពល្អ និងកាយសម្បទាគ្រប់គ្រាន់ក្នុងការបំពេញការងារ ។

**មាត្រា៨.-**

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការត្រូវបើកចំហ ចំពោះមន្ត្រីទាំងឡាយ ដែលមានសញ្ញាបត្រដូចមានចែងក្នុងមាត្រា៧ ខាងលើ និងមានអាយុច្រើនបំផុត ៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

**មាត្រា៩.-**

ការប្រឡងផ្ទៃក្នុង ក្នុងចំណោមមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិត្រូវបើកចំហ ចំពោះមន្ត្រីទាំងឡាយ ដែលមានសញ្ញាបត្រដូចមានចែងក្នុងមាត្រា៧ ខាងលើ ឬ ដែលស្ថិតយ៉ាងតិចបំផុតនៅថ្នាក់លេខ ១១ នៃ ឋានន្តរសក្តិទី ៣ របស់ក្របខណ្ឌឧបការីសវនកម្ម។

**មាត្រា១០.-**

បែបបទលំអិត នៃការប្រឡងជ្រើសរើសមន្ត្រីជាន់ខ្ពស់សវនកម្មនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គសវនករ។

**មាត្រា១១.-**

ក្នុងករណីចាំបាច់ អគ្គសវនករអាចធ្វើសំណើសុំការសម្រេចពីរាជរដ្ឋាភិបាលជ្រើសរើសអ្នកមានជំនាញចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៅអាជ្ញាធរសវនកម្មជាតិ ដើម្បីផលប្រយោជន៍ជាតិ ដោយមិនគិតពីលក្ខខណ្ឌអាយុ។

## ជំពូកទី៤
## កម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម

**មាត្រា១២.-**

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែង ត្រូវធ្វើកម្មសិក្សាក្នុងរយៈពេល÷

- ទី ១ - ១២(ដប់ពីរ)ខែ ចំពោះមន្ត្រីដែលជ្រើសរើសចេញពីនិស្សិត ក្នុងឋានៈជាមន្ត្រីជាន់ខ្ពស់សវនកម្មកម្មសិក្សា ដោយទទួលប្រាក់បៀវត្ស ថ្នាក់លេខ ១៤ នៃឋានន្តរសក្តិទី៣។
- ទី២ - ៦( ប្រាំមួយ)ខែ ចំពោះមន្ត្រីដែលជ្រើសរើសចេញពីក្របខណ្ឌមន្ត្រីរាជការនានា។
- ទី៣ - ៦( ប្រាំមួយ)ខែ ចំពោះមន្ត្រីដែលជ្រើសរើសចេញពីមន្ត្រីក្នុងក្របខណ្ឌអាជ្ញាធរសវនកម្មជាតិក្រៅពីក្របខណ្ឌឧបការីសវនកម្ម។
- ទី៤ - ចំពោះមន្ត្រីដែលជ្រើសរើសចេញពីមន្ត្រីក្នុងក្របខណ្ឌឧបការីសវនកម្ម ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាឡើយ។

ក្រោយពេលធ្វើកម្មសិក្សាបានជោគជ័យ មន្ត្រីដែលមានចែងក្នុងចំណុចទី១ ទី២ និង ទី៣ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិសវនករ នៃក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម។ ក្នុងករណីមន្ត្រីកម្មសិក្សាមិនបានជោគជ័យក្នុងការតាំងស៊ប់ មន្ត្រីនោះអាចត្រូវបានអនុញ្ញាតឱ្យធ្វើកម្មសិក្សាបន្តបន្ថែមដែលមានរយៈពេលអតិបរមាត្រឹម

១២(ដប់ពីរ)ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង៦ (ប្រាំមួយ)ខែ ចំពោះមន្ត្រី ដែលមានចែងក្នុង ចំណុចទី២ និង ទី៣។ មន្ត្រីដែលពុំបានជោគជ័យក្នុងការធ្វើកម្មសិក្សាបន្តបន្ថែម ត្រូវលុបឈ្មោះ ចេញពីមន្ត្រីកម្មសិក្សា ប្រសិនបើចេញពីនិស្សិត ឬ បញ្ជូនទៅក្របខណ្ឌដើមរបស់ខ្លួនវិញ ប្រសិនបើចេញមកពី មន្ត្រីរាជការដោយគិតបញ្ចូលអតីតភាពការងារ។ ករណីខាងក្រោយនេះត្រូវសម្រេចមូលហេតុ ហើយត្រូវធ្វើឡើង ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ខែ ក្រោយការបញ្ចប់កម្មសិក្សា។

**មាត្រា១៣.-**

មន្ត្រីជាន់ខ្ពស់សវនកម្មដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត និងបន្ទាប់ពីធ្វើកម្មសិក្សាសាកល្បងបានជោគជ័យ ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរសក្តិសវនករ ។

មន្ត្រីជាន់ខ្ពស់សវនកម្មដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតាំងស៊ប់ក្នុងឋានន្តរសក្តិសវនករ នៃក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ជំពូកទី៥
## ការតែងតាំង

**មាត្រា១៤.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិសវនករ នៃក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម មន្ត្រីជាន់ខ្ពស់សវនកម្មទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដែលស្របជាមួយ ។

**មាត្រា១៥.-**

មន្ត្រីជាន់ខ្ពស់សវនកម្ម អាចត្រូវបានអនុញ្ញាតឱ្យទៅបម្រើការងារនៅក្រសួង ស្ថាប័នផ្សេងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានការយល់ព្រមពីស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ហើយត្រូវសម្រេចដោយសេចក្តីសម្រេច ប្រកាស អនុក្រឹត្យ ឬ ព្រះរាជក្រឹត្យ ។

## ជំពូកទី៦
## ការដំឡើងថ្នាក់ និងការដំឡើងឋានន្តរសក្តិ

**មាត្រា១៦.-**

មន្ត្រីក្នុងក្របខណ្ឌ នៃមន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវបានដំឡើងថ្នាក់ទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យសម្រាប់ដំឡើងថ្នាក់មានដូចខាងក្រោម ÷

- មានគំនិតផ្តួចផ្តើម និង ច្នៃប្រឌិត

- មានស្មារតីទទួលខុសត្រូវ
- យកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- មានប្រសិទ្ធភាពក្នុងការដឹកនាំ និង
- មានសីលធម៌ល្អ ។

ការដំឡើងថ្នាក់នៃមន្ត្រីក្នុងក្របខណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា១៧.-**

ការដំឡើងឋានន្តរសក្តិ តាមធម្មតាត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ត្រូវដំឡើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

រាល់ការដំឡើងឋានន្តរសក្តិនីមួយៗ នៃក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវអនុវត្តតាមការផ្តល់យោបល់ពីគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម ៖

១ -អគ្គសវនករ ឬ តំណាង ជាប្រធាន

២ -ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក ឬ តំណាង ជាសមាជិក

៣ -ប្រធាននាយកដ្ឋានដែលគ្រប់គ្រងមន្ត្រីសាមី ឬ តំណាង ជាសមាជិក

៤ -តំណាងមន្ត្រីដែលមានក្របខណ្ឌដូចគ្នា ២ (ពីរ) រូបជ្រើសរើសដោយការបោះឆ្នោត ជាសមាជិក ។

**មាត្រា១៨.-**

អាចដំឡើងទៅក្នុងឋានន្តរសក្តិសវនករដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងយ៉ាងតិចបំផុតដល់ថ្នាក់លេខ ១១ នៃឋានន្តរសក្តិសវនករ ។

អាចដំឡើងទៅក្នុងឋានន្តរសក្តិសវនករដើមខ្សែពិសេស គឺមន្ត្រីទាំងឡាយដែលបានឡើងយ៉ាងតិចបំផុតដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិសវនករដើមខ្សែ ។

ការដំឡើងទៅក្នុងឋានន្តរសក្តិមួយខ្ពស់ជាង អាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមី សម្រាប់កាន់មុខតំណែងស្របជាមួយឋានន្តរសក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា៥ នៃលក្ខន្តិកៈដោយឡែកនេះ ។

ការដំឡើងថ្នាក់ក្នុងឋានន្តរសក្តិ សវនករ ត្រូវសម្រេចដោយសេចក្តីសម្រេចរបស់អគ្គសវនករ ។

ការដំឡើងទៅក្នុងឋានន្តរសក្តិសវនករដើមខ្សែ និងការដំឡើងថ្នាក់ក្នុងឋានន្តរសក្តិនេះ ត្រូវសម្រេចដោយអនុក្រឹត្យ ។

ការដំឡើងទៅក្នុងឋានន្តរសក្តិសវនករដើមខ្សែពិសេស និងការដំឡើងថ្នាក់ក្នុងឋានន្តរសក្តិនេះ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

**មាត្រា១៩.-**

មន្ត្រីក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម ដែលមានសញ្ញាបត្រខ្ពស់ជាងបរិញ្ញាបត្រ ឬ សញ្ញាបត្រ សមមូល ត្រូវបានដំឡើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

## ជំពូកទី៧
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា២០.-**

មន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវទទួលប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំ នៃបៀវត្ស អត្ថប្រយោជន៍ ប្រាក់កម្រៃ ប្រាក់រង្វាន់ ព្រមទាំងប្រាក់បំណាច់សវនកម្ម។

**មាត្រា២១.-**

របបកំណត់ស្តីពីថិរវេលាធ្វើការ ការឈប់សម្រាក វិន័យការងារ របៀបរបបការងារ និង អាកប្បកិរិយាការងាររបស់មន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិជ្ជាជីវៈសវនកម្ម។

**មាត្រា២២.-**

ការផ្លាស់ប្តូរ ការបញ្ឈប់ពីការងារ ការដាក់ឱ្យចូលក្នុងស្ថានភាពបាត់បង់សម្បទាវិជ្ជាជីវៈ និងការដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ សេចក្តីសម្រេច ។

**មាត្រា២៣.-**

មន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវដាក់ឱ្យចូលនិវត្តន៍ត្រឹមអាយុ ៦០(ហុកសិប)ឆ្នាំ ។

ចំពោះការដាក់ឱ្យចូលនិវត្តន៍÷

-ការដាក់ឱ្យចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិសវនករដើមខ្សែពិសេស ត្រូវសម្រេចដោយព្រះរាជក្រឹត្យ

-ការដាក់ឱ្យចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិសវនករដើមខ្សែ ត្រូវសម្រេចដោយអនុក្រឹត្យ និង

-ការដាក់ឱ្យចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិសវនករ ត្រូវសម្រេចដោយសេចក្តីសម្រេចរបស់អគ្គសវនករ។

**មាត្រា២៤.-**

សញ្ញាសក្តិ និង ឯកសណ្ឋានសម្រាប់មន្ត្រីក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា២៥.-**

ចំនួនដំបូង នៃក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មត្រូវកសាងចេញពីសមាហរណកម្ម នៃមន្ត្រីទាំងឡាយ ដែលមានជំនាញ មុខតំណែង និងមុខងារពិតប្រាកដកំពុងបំពេញការងារនៅអាជ្ញាធរសវនកម្មជាតិ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២៧.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៩០៧.៧៥៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៧៨៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន